## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

******

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៧៩/០៨ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៨

# គណបក្សនយោបាយចំនួន១១ ចូលរួមប្រកួតប្រជែងជាផ្លូវការ ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមប្រកាសថា មានគណបក្សនយោបាយចំនួន១១ បានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះជាផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤នេះ ហើយគណបក្សទាំងនេះមានដូចតារាងខាងក្រោម:

| ល.រ | ឈ្មោះគណបក្សនយោបាយ | ចំនួនមណ្ឌលឈរឈ្មោះ | ចំនួនបេក្ខជនពេញសិទ្ធិ | | សរុបបេក្ខជនពេញសិទ្ធិ និងបម្រុង | |
|---|---|---|---|---|---|---|
| | | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| 1 | ប្រជាជនកម្ពុជា | 24 | 123 | 20 | 265 | 46 |
| 2 | នរោត្តម រណប្ញទ្ធិ | 24 | 123 | 11 | 264 | 26 |
| 3 | ហង្សវ៉ាចលនាប្រជាធិបតេយ្យ | 24 | 123 | 10 | 264 | 27 |
| 4 | សិទ្ធិមនុស្ស | 24 | 123 | 11 | 264 | 26 |
| 5 | សង្គមយុត្តិធម៌ | 07 | 46 | 18 | 92 | 31 |
| 6 | សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | 24 | 123 | 24 | 264 | 67 |
| 7 | សម រង្ស៊ី | 24 | 123 | 17 | 264 | 33 |
| 8 | ខ្មែរឈប់ក្រ | 07 | 60 | 10 | 120 | 39 |
| 9 | ហ៊្វុនស៊ិនប៉ិច | 24 | 123 | 13 | 264 | 27 |
| 10 | ខ្មែរសាធារណរដ្ឋ | 09 | 72 | 10 | 146 | 25 |
| 11 | ប្រជាធិបតេយ្យខ្មែរ | 24 | 123 | 37 | 271 | 53 |

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨នេះ មានគណបក្សនយោបាយចំនួន១២បានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។ ក្នុងចំណោមគណបក្សទាំង១២នេះ គឺគណបក្សសង្គមខ្មែរនិយមត្រូវបាន គ.ជ.ប បដិសេធដោយសារពុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់កំណត់។

គណបក្សសង្គមខ្មែរនិយមបានដាក់ពាក្យប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី១៧ ខែឧសភា ហើយត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញបើកសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ បដិសេធបណ្តឹង ដោយសំអាងថា ការអនុញ្ញាតឱ្យបំពេញឈ្មោះបេក្ខជន ជំនួសបេក្ខជនដែលគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ពុំមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពិសេសបទបញ្ញត្តិទាំងឡាយដែលទាក់ទងនឹងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។